ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ......០៣៤......ប្រក.សក.ដជគ

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
-បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
-យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីនីតិវិធីនៃការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ការប្រើប្រាស់បណ្ណអនុញ្ញាតបើកបរអន្តរជាតិចេញដោយព្រះរាជាណាចក្រកម្ពុជា និងការប្រើប្រាស់បណ្ណអនុញ្ញាតបើកបរអន្តរជាតិចេញដោយបណ្តាប្រទេសហត្ថលេខីលើអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែន ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩។


មហាវិថី ព្រះនរោត្តម, ភ្នំពេញ
ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៦ ៦៤០, (៨៥៥) ២៣ ៤២៧ ៨៦២

**ប្រការ២.-**

ប្រកាសនេះ អនុវត្តចំពោះការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ និងការគ្រប់គ្រងបណ្ណអនុញ្ញាតបើកបរអន្តរជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែនថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩។

ប្រកាសនេះ មិនអនុវត្តចំពោះបណ្ណបើកបរយានយន្តដែលចេញដោយក្រសួងមហាផ្ទៃ ឬ ក្រសួងការពារជាតិ។

**ប្រការ៣.-**

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

- **បណ្ណអនុញ្ញាតបើកបរអន្តរជាតិ៖** សំដៅដល់បណ្ណអនុញ្ញាតបើកបរយានយន្តដែលចេញដោយបណ្តាប្រទេសហត្ថលេខីលើអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែន ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩ តាមទម្រង់ឯកភាពរួមតែមួយ។ បណ្ណអនុញ្ញាតបើកបរអន្តរជាតិ មានសរសេរជាភាសាអង់គ្លេសថា "International Driving Permit" សរសេរអក្សរកាត់ថា "IDP"។
- **បណ្ណបើកបរជាតិ៖** សំដៅដល់បណ្ណបើកបរយានយន្តដែលចេញដោយប្រទេសនានា ហើយមានតម្លៃប្រើប្រាស់នៅក្នុងប្រទេសទាំងនោះ។

**ប្រការ៤.-**

១. បណ្ណអនុញ្ញាតបើកបរអន្តរជាតិ ជាកូនសៀវភៅដែលមានទំហំ ១៤៨x១០៥ មីលីម៉ែត្រ មានរូបព្រះសង្ហារជានិមិត្តសញ្ញាជាតិ ក្របពណ៌ប្រផេះ សន្លឹកខាងក្នុងពណ៌ស ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

២. ទំព័រទី១(ក្របខាងមុខ) ព័ត៌មានមូលដ្ឋានរបស់បណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសាខ្មែរ និងភាសាអង់គ្លេស។ ទំព័រទី២ វិសាលភាពប្រើប្រាស់បណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសាខ្មែរ។ ទំព័រទី៣ ព័ត៌មានអ្នកកាន់បណ្ណបើកបរ និងប្រភេទបណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសាខ្មែរ។ ទំព័រទី៤ ព័ត៌មានអ្នកកាន់បណ្ណបើកបរ និងប្រភេទបណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសាអង់គ្លេស។ ទំព័រទី៥ ព័ត៌មានអ្នកកាន់បណ្ណបើកបរ និងប្រភេទបណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសាបារាំង។ ទំព័រទី៦ ព័ត៌មានអ្នកកាន់បណ្ណបើកបរ និងប្រភេទបណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសាអេស្ប៉ាញ។ ទំព័រទី៧ ព័ត៌មានអ្នកកាន់បណ្ណបើកបរ និងប្រភេទបណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសារុស្ស៊ី។ ទំព័រទី៨ ព័ត៌មានអ្នកកាន់បណ្ណបើកបរ និងប្រភេទបណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសាចិន។ ទំព័រទី៩ ព័ត៌មានអ្នកកាន់បណ្ណបើកបរ និងប្រភេទបណ្ណអនុញ្ញាតបើកបរអន្តរជាតិ សរសេរជាភាសាអារ៉ាប់។ ទំព័រទី១០ ព័ត៌មានអ្នកកាន់បណ្ណបើកបរមានបិទរូបថត និងប្រភេទយានយន្តអនុញ្ញាតឱ្យបើកបរសរសេរជាភាសាបារាំង។

៣. លេខបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ប្រើប្រាស់លេខ១១(ដប់មួយ)ខ្ទង់ លេខ៣(បី)ខ្ទង់ដំបូងសម្គាល់លេខកូដប្រទេស(៨៥៥) លេខ៨(ប្រាំបី)ខ្ទង់ខាងក្រោយជាលេខបណ្ណបើកបរជាតិ។

**ប្រការ៥.-**

សុពលភាព និងប្រភេទយានយន្ត សម្រាប់បណ្ណអនុញ្ញាតបើកបរអន្តរជាតិ៖

- បណ្ណអនុញ្ញាតបើកបរអន្តរជាតិចេញដោយព្រះរាជាណាចក្រកម្ពុជា មានសុពលភាព១(មួយ)ឆ្នាំស្របតាមអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែន ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩
- ប្រភេទយានយន្តដែលអនុញ្ញាតឱ្យបើកបរ នៅក្នុងបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ត្រូវសមមូលជាមួយប្រភេទយានយន្តដែលអនុញ្ញាតឱ្យបើកបរតាមបណ្ណបើកបរជាតិ ចេញដោយព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

**ប្រការ៦.-**

ការដាក់ពាក្យសុំបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ត្រូវធ្វើតាមប្រព័ន្ធស្វ័យប្រវត្តិកម្មផ្តល់បណ្ណបើកបរយានយន្តដែលមានគេហទំព័រ https://driverlicense.mpwt.gov.kh ឬទៅទីតាំងផ្តល់សេវាសាធារណៈដែលកំណត់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន តាមគំនូសបំព្រួញអំពីដំណើរការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

**ប្រការ៧.-**

ប្រជាពលរដ្ឋខ្មែរ ឬជនបរទេសដែលចូលមកស្នាក់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានបណ្ណបើកបរជាតិចេញដោយព្រះរាជាណាចក្រកម្ពុជា នៅមានសុពលភាពរយៈពេលលើសពី១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណបើកបរ ហើយមានបំណងបើកបរយានយន្តនៅពេលទៅរស់នៅ សិក្សា បេសកកម្ម ឬទេសចរណ៍ នៅបណ្តាប្រទេសហត្ថលេខីលើអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែន ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩ អាចស្នើសុំបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ឯកសារចម្លងបណ្ណបើកបរជាតិចេញដោយព្រះរាជាណាចក្រកម្ពុជា
- ឯកសារចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន(ចំពោះជនបរទេស)
- ឯកសារចម្លងកិច្ចសន្យាជួលផ្ទះដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច និងលិខិតបញ្ជាក់អាសយដ្ឋានបច្ចុប្បន្នចេញដោយមេឃុំ ឬចៅសង្កាត់(ចំពោះជនបរទេស)
- រូបថត ៤x៦ ផ្ទៃពណ៌ស ៣សន្លឹក។

ទម្រង់ពាក្យសុំបណ្ណអនុញ្ញាតបើកបរអន្តរជាតិ មានចែងក្នុងឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

**ប្រការ៨.-**

ករណីបណ្ណអនុញ្ញាតបើកបរអន្តរជាតិអស់សុពលភាព ខូច ឬបាត់ អ្នកកាន់បណ្ណអនុញ្ញាតបើកបរអាចស្នើសុំបណ្ណអនុញ្ញាតបើកបរអន្តរជាតិសារជាថ្មីឡើងវិញ ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារដូចមានចែងក្នុងប្រការ៧នៃប្រកាសនេះ។ អ្នកស្នើសុំ ត្រូវភ្ជាប់មកជាមួយផងដែរនូវពាក្យបណ្តឹងដែលទទួលស្គាល់ ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៩.-**

អ្នកកាន់បណ្ណអនុញ្ញាតបើកបរអន្តរជាតិចេញដោយព្រះរាជាណាចក្រកម្ពុជា នៅពេលបើកបរយានយន្តនៅបណ្តាប្រទេសហត្ថលេខីលើអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែន ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩ ត្រូវដាក់ភ្ជាប់តាមខ្លួននូវបណ្ណអនុញ្ញាតបើកបរអន្តរជាតិ និងបណ្ណបើកបរជាតិ ព្រមទាំងគោរពតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសដែលអ្នកបើកបរកំពុងចរាចរណ៍យានយន្ត។

បណ្ណអនុញ្ញាតបើកបរអន្តរជាតិដែលចេញដោយព្រះរាជាណាចក្រកម្ពុជា ពុំមានសុពលភាពប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

បញ្ជីឈ្មោះបណ្តាប្រទេសហត្ថលេខីលើអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែន ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩ មានចែងក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

**ប្រការ១០.-**

អ្នកកាន់បណ្ណអនុញ្ញាតបើកបរអន្តរជាតិដែលចេញដោយបណ្តាប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែន ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩ នៅពេលបើកបរយានយន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ភ្ជាប់តាមខ្លួននូវបណ្ណអនុញ្ញាតបើកបរអន្តរជាតិ និងបណ្ណបើកបរជាតិដែលផ្តល់ស្របតាមប្រភេទយានកំពុងចរាចរ ព្រមទាំងគោរពតាមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១១.-**

បណ្ណអនុញ្ញាតបើកបរអន្តរជាតិ អាចត្រូវបានដកហូតព្យួរទុកមួយរយៈពេល ប្រសិនបើអ្នកបើកបរប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសដែលអ្នកបើកបរកំពុងចរាចរយានយន្ត ប៉ុន្តែរយៈពេលនៃការដកហូតព្យួរបណ្ណអនុញ្ញាតបើកបរអន្តរជាតិ មិនលើសពីរយៈពេលទិដ្ឋាការស្នាក់នៅរបស់អ្នកកាន់បណ្ណអនុញ្ញាតបើកបរក្នុងប្រទេសនោះឡើយ។

**ប្រការ១២.-**

ការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ត្រូវបង់កម្រៃសេវាសាធារណៈតាមការកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ១៣.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ត្រូវគ្រប់គ្រងការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ តាមដាន ត្រួតពិនិត្យ និងណែនាំការប្រើប្រាស់បណ្ណអនុញ្ញាតបើកបរអន្តរជាតិ។

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ......................ខែ..............ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....១៥.....ខែ.....មករា.....ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៥ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

ទម្រង់បណ្ណអនុញ្ញាតបើកបរអន្តរជាតិ

ប្រកាសលេខ ០៣៧ ប្រក.សាធ.ដក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២០

ស្តីពីនីតិវិធីនៃការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ

## ទំព័រទី១

(ផ្នែកខាងក្រៅនៃក្របខាងមុខ)

**ព្រះរាជាណាចក្រកម្ពុជា**

KINGDOM OF CAMBODIA

**បណ្ណអនុញ្ញាតបើកបរអន្តរជាតិ**

INTERNATIONAL DRIVING PERMIT

**អនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩**

Convention on International Road Traffic of 19 September 1949

**បណ្ណអនុញ្ញាតបើកបរលេខ**

PERMIT No. ..................................................................

**ថ្ងៃចេញបណ្ណ**

DATE OF ISSUE ..........................................................

**ថ្ងៃផុតកំណត់**

EXPIRY DATE ..............................................................

**អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក**

GENERAL DEPARTMENT OF LAND TRANSPORT

# ទំព័រទី២

(ផ្នែកខាងក្នុងនៃក្របខាងមុខ)

បណ្ណអនុញ្ញាតបើកបរអន្តរជាតិនេះ ពុំមានសុពលភាពប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

បណ្ណអនុញ្ញាតបើកបរអន្តរជាតិនេះ មានសុពលភាព ១ (មួយ)ឆ្នាំ អាចប្រើប្រាស់នៅក្នុងបណ្តាប្រទេសហត្ថលេខីលើអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែន ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩ និងប្រភេទយានយន្តដែលអនុញ្ញាតត្រូវបានបញ្ជាក់នៅទំព័រចុងក្រោយនៃបណ្ណបើកបរនេះ។

នៅពេលបើកបរយានយន្តនៅក្រៅប្រទេស អ្នកបើកបរដែលមានបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ត្រូវយកភ្ជាប់តាមខ្លួននូវបណ្ណបើកបរជាតិ និងលិខិតឆ្លងដែន។

# ទំព័រទី៣

## ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរ ជាភាសាខ្មែរ

**ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរ**

*នាម 1*
*គោត្តនាម 2*
*ទីកន្លែងកំណើត 3*
*ថ្ងៃ-ខែ-ឆ្នាំកំណើត 4*
*ទីលំនៅអចិន្ត្រៃយ៍ 5*

**យានយន្តដែលអនុញ្ញាតឱ្យបើកបរ៖**

| | |
|---|---|
| ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងលើសពី១២៥សង់ទីម៉ែត្រគូប ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក និងត្រីចក្រយានយន្ត | **ក** |
| រថយន្តដឹកអ្នកដំណើរមិនលើសពី៩នាក់ ដោយគិតទាំងអ្នកបើកបរ។ រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាមិនលើសពី៣,៥តោន។ រថយន្តក្នុងប្រភេទនេះ អាចសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥តោន | **ខ** |
| រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាលើសពី៣,៥តោន និងអាចសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី០,៧៥តោន | **គ** |
| **ឃ១** : រថយន្តដឹកអ្នកដំណើរចាប់ពី១០នាក់ ដល់២០នាក់ ដោយគិតទាំងអ្នកបើកបរ<br>**ឃ២** : រថយន្តដឹកអ្នកដំណើរលើសពី២០នាក់ ដោយគិតទាំងអ្នកបើកបរ រថយន្តក្នុងប្រភេទនេះ អាចសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមា មិនលើសពី០,៧៥តោន | **ឃ** |
| រថយន្តប្រភេទ **ខ គ** និង **ឃ** មានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាលើសពី០,៧៥តោន ត្រូវចែកជាបីប្រភេទ គឺប្រភេទ **ង**(**ខ**) ប្រភេទ **ង**(**គ**) និងប្រភេទ **ង**(**ឃ**) | **ង** |

*«ទម្ងន់សរុបអនុញ្ញាតអតិបរមា»របស់យាន សំដៅដល់ផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញអនុញ្ញាត។«ទម្ងន់ផ្ទុកអតិបរមារ»របស់យាន សំដៅដល់ផលបូកទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញ ដែលកំណត់ដោយរោងចក្រផលិតយាន។*

| | |
|---|---|
| **ការមិនអនុញ្ញាត**<br>អ្នកកាន់បណ្ណនេះ មិនមានសិទ្ធិបើកបរក្នុង(ប្រទេស)៖<br>..........................................................................<br>មូលហេតុ៖..........................................................<br>(បោះត្រាអាជ្ញាធរ) ទីកន្លែង ៖.........................................<br>កាលបរិច្ឆេទ៖.........................................<br>ហត្ថលេខា ៖.........................................<br>ប្រសិនបើកន្លែងទំនេរខាងលើបានបំពេញ ហើយត្រូវការកន្លែងបន្ថែម សូមប្រើកន្លែងទំនេរដែលទុកសម្រាប់ «ការមិនអនុញ្ញាត» | **ការមិនអនុញ្ញាត**<br>(ប្រទេស I-VIII) |

# ទំព័រទី៤

## ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរ ជាភាសាអង់គ្លេស

Particulars concerning the Driver

*Surname 1*
*Other names 2*
*Place of birth 3*
*Date of birth 4*
*Permanent place of residence 5*

Vehicles for which the permit is valid:

| | |
|---|---|
| Motor cycles with the cylindrical size over 125 $cm^3$ or more than 11 kW. Motorcycles with trailers and tricycles. | A |
| Motor vehicles used for the transport of passengers not over 9 passengers including the driver. Motor vehicles used for the transport of goods and having a permissible maximum weight not exceeding 3.5 tons. Vehicles in this category may be coupled with a trailer maximum weight not exceeding 0.75 tons. | B |
| Motor vehicles used for the transport of goods and of which the permissible maximum weight exceeding 3.5 tons. Vehicles in this category may be coupled with a trailer maximum weight not exceeding 0.75 tons. | C |
| D1 : Motor vehicles used for the transport of passengers from 10 to 20 passengers.<br>D2 : Motor vehicles used for the transport of passengers exceeding 20 passengers. Vehicles in this category may be coupled with a trailer maximum weight not exceeding 0.75 tons. | D |
| Motor vehicles of categories B, C or D may be coupled with other than trailers maximum weight exceeding 0.75 tons, divided into 3 types: BE, CE or DE. | E |

*«Total maximum authorized weight» of vehicle refers to the sum of the net weight of the vehicle and authorized carrying weight of passengers and goods. «Maximum carrying weight» of vehicle refers to the sum of the loading weight of both passengers and goods as defined by its factory.*

| EXCLUSION | EXCLUSIONS (Countries I-VIII) |
|---|---|
| Holder of this permit is deprived of the right to drive in (Country)........................................................................<br>By reason of....................................................................<br>Seal or stamp of authority — Place ..................................................... Date ........................................................ Signature ..............................................<br>Should the above space be already filled, use any other space provided for «Exclusion» | |

# ទំព័រទី៥

## ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរ ជាភាសាបារាំង

Indications relatives au conducteur

*Nom 1*

*Autres noms 2*

*Lieu de naissance 3*

*Date de naissance 4*

*Lieu de résidence permanent 5*

Véhicules pour lesquels le permis est valide:

| | |
|---|---|
| Motocycles de cylindrée supérieure à 125 $cm^3$ ou supérieure à 11 kW. Motos avec remorques et tricycles. | A |
| Véhicules à moteur utilisés pour le transport de passagers d'au plus 9 passagers, chauffeur inclus. Véhicules à moteur utilisés pour le transport de marchandises et dont le poids maximal autorisé n'excède pas 3,5 tonnes. Les véhicules de cette catégorie peuvent être associés à un poids maximal de la remorque ne dépassant pas 0,75 tonne. | B |
| Véhicules à moteur utilisés pour le transport de marchandises et dont le poids maximal autorisé dépasse 3,5 tonnes. Les véhicules de cette catégorie peuvent être associés à un poids maximal de la remorque ne dépassant pas 0,75 tonne. | C |
| D1: Véhicules à moteur utilisés pour le transport de passagers de 10 à 20 passagers.<br>D2: Véhicules à moteur utilisés pour le transport de passagers de plus de 20 passagers. Les véhicules de cette catégorie peuvent être associés à un poids maximal de la remorque ne dépassant pas 0,75 tonne. | D |
| Les véhicules à moteur des catégories B, C ou D peuvent être attelés avec un poids maximal autre que celui des remorques supérieur à 0,75 tonne, répartis en 3 types: BE, CE ou DE. | E |

Le «poids total maximum autorisé» du véhicule correspond à la somme du poids net du véhicule et du poids autorisé des passagers et des marchandises. La «masse maximale de transport» du véhicule correspond à la somme du poids de chargement des passagers et des marchandises tel que défini par son usine.

| EXCLUSION | EXCLUSIONS<br>(Des pays I-VIII) |
|---|---|
| Le titulaire de ce permis est privé du droit de conduire (pays)....................<br>En raison de....................<br>(Sceau ou cachet de l'autorité) Llieu ....................<br>Date ....................<br>Signature .................... | |
| Si l'espace ci-dessus est déjà rempli, utilisez tout autre espace prévu à cet effet «Exclusion» | |

# ទំព័រទី៦

## ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរ ជាភាសាអេស្ប៉ាញ

Datos relativos al conductor

*Apellido 1*
*Otros nombres 2*
*Lugar de nacimiento 3*
*Fecha de nacimiento 4*
*Lugar de residencia permanente 5*

Vehículos para los cuales el permiso es válido:

| | |
|---|---|
| iclos de motor con el tamaño cilíndrico superior a 125 $cm^3$ o superior a 11 kW. Motocicletas con remolques y triciclos. | A |
| ehículos de motor utilizados para el transporte de pasajeros no mayores de 9 pasajeros, incluido el conductor. Vehículos de motor utilizados para el transporte de mercancías y que tengan un peso máximo permitido no superior a 3,5 toneladas. Los vehículos en esta categoría se pueden acoplar con un peso máximo del remolque que no exceda de 0,75 toneladas. | B |
| Vehículos de motor utilizados para el transporte de mercancías y cuyo peso máximo permitido exceda de 3,5 toneladas. Los vehículos en esta categoría se pueden acoplar con un peso máximo del remolque que no exceda de 0,75 toneladas. | C |
| D1: Vehículos de motor utilizados para el transporte de pasajeros de 10 a 20 pasajeros.<br>D2: Vehículos de motor utilizados para el transporte de pasajeros de más de 20 pasajeros. Los vehículos en esta categoría se pueden acoplar con un peso máximo del remolque que no exceda de 0,75 toneladas. | D |
| Los vehículos motorizados de las categorías B, C o D se pueden acoplar con otro peso que no sea de remolques que exceda de 0,75 toneladas, dividido en 3 tipos: BE, CE o DE. | E |

*«Peso máximo autorizado total» del vehículo se refiere a la suma del peso neto del vehículo y el peso autorizado para el transporte de pasajeros y mercancías. El "peso máximo de transporte" del vehículo se refiere a la suma del peso de carga tanto de los pasajeros como de las mercancías tal como lo define su fábrica.*

| EXCLUSIÓN | EXCLUSIÓN (Países I-VIII) |
|---|---|
| El titular de este permiso está privado del derecho a conducir (País)........................................<br>Por razón de........................................<br>Sello o sello de autoridad<br>Lugar........................................<br>Fecha........................................<br>Firma........................................ | |
| Si el espacio anterior ya está ocupado, utilice cualquier otro espacio provisto para la «Exclusión» | |

# ទំព័រទី៧

## ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរ ជាភាសារុស្ស៊ី

Подробности относительно водителя

*Фамилия 1*

*Другие имена 2*

*Место рождения 3*

*Дата рождения 4*

*Постоянное место жительства 5*

Транспортные средства, на которые действует разрешение:

| | |
|---|---|
| Мотоциклы с цилиндрическим размером свыше 125 см3 или более 11 кВт. Мотоциклы с прицепами и трехколесными велосипедами. | A |
| Автомобили, предназначенные для перевозки пассажиров не более 9 пассажиров, включая водителя. Автомобили, предназначенные для перевозки грузов и имеющие максимальный допустимый вес, не превышающий 3,5 тонны. Транспортные средства этой категории могут сочетаться с максимальным весом прицепа не более 0,75 тонн. | B |
| Автомобили, используемые для перевозки грузов, из которых допустимый максимальный вес превышает 3,5 тонны. Транспортные средства этой категории могут сочетаться с максимальным весом прицепа не более 0,75 тонн. | C |
| D1: Автомобили, используемые для перевозки пассажиров от 10 до 20 пассажиров.<br>D2: Автомобили, используемые для перевозки пассажиров, превышающих 20 пассажиров. Транспортные средства этой категории могут сочетаться с максимальным весом прицепа не более 0,75 тонн. | D |
| Автомобили категорий B, C или D могут сочетаться с прицепами, максимальный вес которых превышает 0,75 тонны, и делятся на 3 типа: BE, CE или DE. | E |

*«Общий максимальный разрешенный вес» транспортного средства относится к сумме нетто-веса транспортного средства и разрешенного веса пассажиров и грузов. «Максимальный вес перевозимого транспортного средства» относится к сумме веса погрузки как пассажиров, так и грузов, как определено его заводом.*

| ИСКЛЮЧЕНИЕ | ИСКЛЮЧЕНИЕ (Страны I-VIII) |
|---|---|
| Обладатель этого разрешения лишен права на въезд в страну (страну)..............................................................<br>По причине.....................................................................<br>Печать или печать власти<br>Место....................................................<br>Дата......................................................<br>Подпись................................................ | |
| Если вышеуказанное пространство уже заполнено, используйте любое другое место, предусмотренное для «Исключения» | |

# ទំព័រទី៨

## ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរ ជាភាសាចិន

有關司機的詳情

*姓氏1*
*其他名稱2*
*出生地3*
*出生日期4*
*永久居住地5*

許可證有效的車輛：

| | |
|---|---|
| 圓柱形尺寸超過125 $cm^3$ 或超過11 kW 的電動機。<br>摩托車與拖車和三輪車。 | A |
| 用於運送不超過9名乘客（包括司機）的乘客的機動車輛。 用於運輸貨物的機動車輛，允許的最大重量不超過3.5噸。 此類車輛可與拖車最大重量不超過0.75噸相結合。 | B |
| 用於運輸貨物的機動車輛，允許的最大重量超過3.5噸。 此類車輛可與拖車最大重量不超過0.75噸相結合。 | C |
| D1：用於運送10至20名乘客的機動車輛。<br>D2：用於運送超過20名乘客的乘客的機動車輛。 此類車輛可與拖車最大重量不超過0.75噸相結合。 | D |
| B，C或D類機動車可以與最大重量超過0.75噸的拖車以外的其他車輛連接，分為3種類型：BE，CE或DE。 | E |

*"車輛的最大授權總重量"是指車輛的淨重與乘客和貨物的授權承載重量之和。 車輛的"最大承載重量"是指其工廠規定的乘客和貨物的裝載重量之和。*

| 排除 | 排除 |
|---|---|
| 持有此許可證的人被剝奪了開車的權利（國家）<br>..........................................................................................<br>由於..................................................................................<br>地點....................................................<br>日期....................................................<br>簽名....................................................<br>印章或印章的權威 | (國家I-VIII) |
| 如果上述空間已經填滿，請使用為"排除"提供的任何其他空間 | |



# ទំព័រទី៩

## ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរ ជាភាសាអារ៉ាប់

تفاصيل بشأن السائق

اللقب 1
أسماء أخرى 2
مكان الميلاد 3
تاريخ الميلاد 4
مكان الإقامة الدائم 5

:المركبات التي يكون تصريحها ساري المفعول

| | |
|---|---|
| A | دورات بمحرك بحجم أسطواني يزيد عن 125 سم 3 أو أكثر من 11 كيلو وات. الدراجات النارية مع المقطورات والدراجة ذات العجلات الثلاث. |
| B | السيارات التي تستخدم لنقل الركاب لا يزيد عن 9 ركاب بما في ذلك السائق. السيارات المستخدمة لنقل البضائع والتي لا يزيد وزنها المسموح به عن 3.5 طن. قد يقترن المركبات في هذه الفئة بوزن مقطورة لا يتجاوز 0.75 طن. |
| C | السيارات المستخدمة في نقل البضائع والتي يزيد وزنها الأقصى المسموح به عن 3.5 طن. قد يقترن المركبات في هذه الفئة بوزن مقطورة لا يتجاوز 0.75 طن. |
| D | D1: السيارات المستخدمة لنقل الركاب من 10 إلى 20 راكب.<br>D2: السيارات المستخدمة لنقل الركاب التي تتجاوز 20 راكبا. قد يقترن المركبات في هذه الفئة بوزن مقطورة لا يتجاوز 0.75 طن. |
| E | بخلاف المقطورات التي يزيد وزنها عن 0.75 طن ، مقسمة إلى D أو C أو B يمكن أن تقترن المركبات من الفئات 3 أنواع: BE أو CE أو DE. |

*يشير "إجمالي الوزن الأقصى المسموح به" للمركبة إلى مجموع الوزن الصافي للمركبة والوزن المسموح به لحمل الركاب والبضائع. يشير "أقصى وزن حمل" للمركبة إلى مجموع وزن التحميل لكل من الركاب والبضائع على النحو المحدد في مصنعها.*

| | |
|---|---|
| استثناء<br>(الدول من الأول إلى الثامن) | استثناء<br>يُحرم حامل هذا التصريح من حق القيادة في (البلد)..............................<br>..............................<br>بسبب..............................<br>مكان..............................<br>تاريخ..............................<br>التوقيع..............................<br>ختم أو ختم السلطة<br>«إذا تم ملء المساحة أعلاه بالفعل ، استخدم أي مساحة أخرى متوفرة لـ «الاستبعاد |

# ឧបសម្ព័ន្ធទី១០

## ព័ត៌មានអ្នកកាន់បណ្ណអនុញ្ញាតបើកបរមានបិទរូបថត និងប្រភេទយានយន្តអនុញ្ញាតឱ្យបើកបរ

*1* ..............................................................................................

*2* ..............................................................................................

*3* ..............................................................................................

*4* ..............................................................................................

*5* ..............................................................................................

| | |
|---|---|
| A | Sceau ou cachet de l'autorité |
| B | Sceau ou cachet de l'autorité |
| C | Sceau ou cachet de l'autorité |
| D | Sceau ou cachet de l'autorité |
| E | Sceau ou cachet de l'autorité |

Photographie

Sceau ou cachet de l'autorité

Signature du titulaire

EXCLUSIONS:

(pays I-VIII)

| | |
|---|---|
| I ............................................ | V ............................................ |
| II ............................................ | VI ............................................ |
| III ............................................ | VII ............................................ |
| IV ............................................ | VIII............................................ |

# ឧបសម្ព័ន្ធទី២

## តារាងសមមូលបណ្ណអនុញ្ញាតបើកបរអន្តរជាតិជាមួយនឹងបណ្ណបើកបរជាតិ

ប្រកាសលេខ ០៣៧/ក្រ.សាក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២០

ស្តីពីនីតិវិធីនៃការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ

| **បណ្ណបើកបរជាតិ** | **បណ្ណអនុញ្ញាតបើកបរអន្តរជាតិ** |
|---|---|
| ប្រភេទ **ក** | ប្រភេទ A |
| ប្រភេទ **ខ** | ប្រភេទ B |
| ប្រភេទ **គ** | ប្រភេទ C |
| ប្រភេទ **ឃ១** | ប្រភេទ D1 |
| ប្រភេទ **ឃ២** | ប្រភេទ D2 |
| ប្រភេទ **ង(ខ)** | ប្រភេទ BE |
| ប្រភេទ **ង(គ)** | ប្រភេទ CE |
| ប្រភេទ **ង(ឃ)** | ប្រភេទ DE |

# ឧបសម្ព័ន្ធទី៣

## គំនូសបំព្រួញអំពីដំណើរការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ

ប្រកាសលេខ ០៧២ ប្រក.ឈក.ឈស ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២០

ស្តីពីនីតិវិធីនៃការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ



## ឧបសម្ព័ន្ធទី៤

ទម្រង់ពាក្យសុំបណ្ណអនុញ្ញាតបើកបរអន្តរជាតិ

ប្រកាសលេខ០៣៧/ប្រក.សដ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២០

ស្តីពីនីតិវិធីនៃការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ

**ព្រះរាជាណាចក្រកម្ពុជា**

KINGDOM OF CAMBODIA

**ជាតិ សាសនា ព្រះមហាក្សត្រ**

NATION RELIGION KING

# ពាក្យសុំបណ្ណអនុញ្ញាតបើកបរអន្តរជាតិ

**APPLICATION FORM FOR EXCHANGE OF INTERNATIONAL PERMIT**

នាម និងគោត្តនាម/Name and Surname..................................................ភេទ/Sex....................

កើតនៅថ្ងៃទី-ខែ-ឆ្នាំ/Date of birth ........./.........../............សញ្ជាតិ/Nationality..............................

អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ/Address#........................ផ្លូវលេខ/Street No..............................

សង្កាត់-ឃុំ/Sangkat-Commune........................ខណ្ឌ-ក្រុង-ស្រុក/Khan-Town-District...............

រាជធានី-ខេត្ត/City-Province..............................លេខទូរសព្ទ/Phone No..................................

លិខិតឆ្លងដែនលេខ/Passport No....................ផ្តល់នៅថ្ងៃ/Date of Issue........../.........../...........

បណ្ណបើកបរលេខ/Driving Licence No................. ថ្ងៃចេញបណ្ណ/Date of Issue........./......../.......

មូលហេតុស្នើសុំបណ្ណអនុញ្ញាតបើកបរអន្តរជាតិ/ Purpose of application for International Driving Permit...........................................................................................................................

..........................................................................................................................................

ខ្ញុំសូមធានាអះអាងថាព័ត៌មានខាងលើពិតជាត្រឹមត្រូវប្រាកដមែន។

I certify that all the information included in this application and attached documents is correct and true.

...........ថ្ងៃទី/Date...........ខែ/Month..........ឆ្នាំ/Year........

ហត្ថលេខា ឬស្នាមមេដៃ/Signature or Fingerprint

**ឯកសារភ្ជាប់**/Attachments៖

- លិខិតឆ្លងដែន/Passport
- បណ្ណបើកបរជាតិ/Driver's License

# ឧបសម្ព័ន្ធទី៥

## បញ្ជីឈ្មោះបណ្តាប្រទេសហត្ថលេខីលើអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ទីក្រុងវីយែនថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩

ប្រកាសលេខ០៣៦ប្រក.គសណចុះថ្ងៃទី.....១៥.....ខែ.មករា.....ឆ្នាំ២០២០

ស្តីពីនីតិវិធីនៃការចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិ

| ល.រ | ឈ្មោះប្រទេស | ល.រ | ឈ្មោះប្រទេស | ល.រ | ឈ្មោះប្រទេស |
|---|---|---|---|---|---|
| ១ | Albania | ៣៤ | Haiti | ៦៧ | Peru |
| ២ | Algeria | ៣៥ | Holy See | ៦៨ | Philippines |
| ៣ | Argentina | ៣៦ | Hungary | ៦៩ | Poland |
| ៤ | Australia | ៣៧ | Iceland | ៧០ | Portugal |
| ៥ | Austria | ៣៨ | India | ៧១ | Republic of Korea |
| ៦ | Bangladesh | ៣៩ | Ireland | ៧២ | Romania |
| ៧ | Barbados | ៤០ | Israel | ៧៣ | Russian Federation |
| ៨ | Belgium | ៤១ | Italy | ៧៤ | Rwanda |
| ៩ | Benin | ៤២ | Jamaica | ៧៥ | San Marino |
| ១០ | Botswana | ៤៣ | Japan | ៧៦ | Senegal |
| ១១ | Bulgaria | ៤៤ | Jordan | ៧៧ | Serbia |
| ១២ | Burkina Faso | ៤៥ | Kyrgyzstan | ៧៨ | Sierra Leone |
| ១៣ | Cambodia | ៤៦ | Lao People's Democratic Republic | ៧៩ | Singapore |
| ១៤ | Canada | ៤៧ | Lebanon | ៨០ | Slovakia |
| ១៥ | Central African Republic | ៤៨ | Lesotho | ៨១ | Slovenia |
| ១៦ | Chile | ៤៩ | Lithuania | ៨២ | South Africa |
| ១៧ | Congo | ៥០ | Luxembourg | ៨៣ | Spain |
| ១៨ | Côte d'Ivoire | ៥១ | Madagascar | ៨៤ | Sri Lanka |
| ១៩ | Cuba | ៥២ | Malawi | ៨៥ | Sweden |
| ២០ | Cyprus | ៥៣ | Malaysia | ៨៦ | Switzerland |
| ២១ | Czech Republic | ៥៤ | Mali | ៨៧ | Syrian Arab Republic |
| ២២ | Democratic Republic of the Congo | ៥៥ | Malta | ៨៨ | Thailand |
| ២៣ | Denmark | ៥៦ | Monaco | ៨៩ | Togo |
| ២៤ | Dominican Republic | ៥៧ | Montenegro | ៩០ | Trinidad and Tobago |
| ២៥ | Ecuador | ៥៨ | Morocco | ៩១ | Tunisia |
| ២៦ | Egypt | ៥៩ | Namibia | ៩២ | Turkey |
| ២៧ | Fiji | ៦០ | Netherlands | ៩៣ | Uganda |
| ២៨ | Finland | ៦១ | New Zealand | ៩៤ | United Arab Emirates |
| ២៩ | France | ៦២ | Niger | ៩៥ | United Kingdom of Great Britain and Northern Ireland |
| ៣០ | Georgia | ៦៣ | Nigeria | ៩៦ | United States of America |
| ៣១ | Ghana | ៦៤ | Norway | ៩៧ | Venezuela(Bolivarian Republic of) |
| ៣២ | Greece | ៦៥ | Papua New Guinea | ៩៨ | Viet Nam |
| ៣៣ | Guatemala | ៦៦ | Paraguay | ៩៩ | Zimbabwe |